អង្គការសាលារៀនទន្សាយ

របាយការណ៍ប្រចាំឆ្នាំ ២០២៣

អាសយដ្ឋាន៖ ស្ថិតក្នុងសាលាបឋមសិក្សាទួលគោក វិថី២៨៩ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទទំនាក់ទំនង៖ ០១២៣៦៩៣៧៦

អ៊ីម៉ែល៖ huntouch40@gmail.com

គេហទំព័រ៖ www.rabbitschoolcambodia.net.

Content

Glossary of Acronyms 3
1. Annual Financial Report 2023 .....**Error! Bookmark not defined.**4
2. Executive Summary .....**Error! Bookmark not defined.**6
3. Challenges, Issues and Strategies .....**Error! Bookmark not defined.**14
4. Strategies will take action for next plan: .....**Error! Bookmark not defined.**14
5. Sustainability .....**Error! Bookmark not defined.**14
6. Monitoring and Evaluation Activities .....**Error! Bookmark not defined.**15
7. Communication and Visibility of project .....**Error! Bookmark not defined.**15
18. Case Study .....**Error! Bookmark not defined.**16
9. Annex: Pictures .....**Error! Bookmark not defined.**18


RSO

Glossary of Acronyms


Acronyms/Abbreviations	Full words
MoSVY	Ministry of Social Veteran and Youth Rehabilitation
MoEYS	Ministry of Education Youth and Sport
PoSVY,	Provincial of Social Veteran and Youth Rehabilitation
PoE	Provincial Office of Education
DoSVY	District of Social Veteran and Youth Rehabilitation
DoE	District Office of Education
DTMT	District Training and Monitoring Team
SSC	School Support Committee
SD	School Director
DCWC	District Council for Woman and Children
CCWC	Commune Council for Woman and Children
CWID	Children with Intellectual Disabilities
OOSC	Out Of School Children
PwDs	Person with Disability
YwID	Youth with Intellectual disability
NGO	Non-Government Organization
RSO	Rabbit School Organization
NISE	National Institute for Special Education
EPC	Essential Personal Ceter
HI	Human Inclusion
PPCIL	Phnom Penh Center for Independent Living - PPCIL
RTI	Research Triangle Institute
CRS	Catholic Relief Service
NEP	NGO Education Partnership
NEA	National Employment Agency
GMAC	Garment Manufacturers Association in Cambodia
HHC	Hand of Hope Community

១. របាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ ២០២៣

ចំណូលពីថ្នាស់ជំនួយ	ចំនួន
អេដ អេរអាក់ស្យុងកម្ពុជា	$ 100,422.09
មូលនិធិកុមារកម្ពុជា	$ 20,000.00
មជ្ឈមណ្ឌលស្រាវជ្រាវ RCI	$ 15,562.33
ចំណូលផ្សេង	$ 27,800.37
បដិភាគអាណាព្យាបាល	$ 25,587.55
សកម្មភាពប្រជាជនសម្រាប់ការអភិវឌ្ឍន៍រួម	$ 500.00
រលត្រាស	$ 19,450.80
មេនូឡាយហ្វ៍	$ 11,282.00
អ៊ុកស្វាម កម្ពុជា	$ 4,965.79
សរុប	$ 225,570.93



ចំណាយ	ចំនួន
ធនធានមនុស្ស	$ 81,810.60
ការធ្វើដំណើរ	$ 2,826.54
ឧបករណ៍និងសំភារៈផ្គត់ផ្គង់	$ 521.50
គ្រឿងបរិក្ខារក្នុងស្រុក	$ 8,736.56
ចំណាយលើសកម្មភាព	$ 132,574.90
សរុប	$ 226,470.10



២. រចាយឆ្នាំសង្ខេប

អង្គការសាលាទន្សាយ មានកម្មវិធីអប់រំពិសេសដើម្បីជួយអភិវឌ្ឍកុមារដែលមានពិការភាពសតិបញ្ញា និងដើម្បីធ្វើការងារឆ្ពោះទៅរកការធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គម។ កុមារអាចចុះឈ្មោះចូលរៀននៅសាលារៀនទន្សាយបាន ចាប់ពីអាយុ ៤ឆ្នាំឡើងទៅ ហើយនឹងទទួលបានការគាំទ្ររហូតដល់អាយុ ២៥ ឆ្នាំ។

នៅដំណាក់កាលនីមួយៗនៃកម្មវិធីរបស់សាលារៀនទន្សាយ សិស្សទាំងអស់ត្រូវបានវាយតម្លៃ គាំទ្រ និងអប់រំតាមរបៀបដែលត្រូវបានរៀបចំឡើងជាពិសេសដើម្បីឆ្លើយតបតម្រូវការរបស់សិស្ស។ កុមារម្នាក់ៗត្រូវបានលើកទឹកចិត្តឱ្យមានវឌ្ឍនភាព និងឯករាជ្យភាពជាងមុន ដោយគិតគូរពីលក្ខណៈផ្ទាល់ខ្លួន និងគោលដៅរបស់ពួកគេជានិច្ច។

កម្មវិធីអប់រំរបស់សាលាទន្សាយត្រូវបានរួមបញ្ចូលការចូលរៀនក្នុងការអប់រំពិសេស ការអប់រំរួមបញ្ចូលគ្នា និងរួមបញ្ចូល ការបណ្តុះបណ្តាលមុនវិជ្ជាជីវៈ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការផ្តល់ការងារ និងការបញ្ចូលទៅក្នុងសង្គមឡើងវិញនៅអាយុ 25 ឆ្នាំ។

សាលារៀនទន្សាយបានរៀបចំរបាយការណ៍ប្រចាំឆ្នាំនេះ ជារបាយការណ៍អនុវត្តគម្រោងរបស់ខ្លួនរយៈពេលមួយឆ្នាំចាប់ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៣។

លទ្ធផលទី ១៖ កុមារក្រៅសាលាបានទទួលឱកាសចូលរៀនកម្រិតបឋមប្រសើរឡើងប្រកបដោយសមធម៌។

កុមារមានពិការភាពចំនួន ២២១នាក់ (ស្រី៖ ៦៤) ក្នុងគម្រោងដំណាក់កាលទី១ បានបន្តទទួលសេវាក្នុងឆ្នាំនេះ ក្នុងនោះសិស្សចំនួន ៣៦នាក់ (ស្រី៖ ១១) បានបោះបង់ការសិក្សា សិស្សចំនួន ៤៤នាក់ (ស្រី៖ ១៣) ចាកចេញពីគម្រោងដោយសារពួកគេបានឡើងថ្នាក់ទៅរៀននៅកម្រិតអនុវិទ្យាល័យ។

ការជុសជុលថ្នាក់អប់រំបរិយាប័ន្ន រួមមានបង្គន់ ជម្រាល និងបន្ទប់ថ្នាក់បរិយាប័ន្នក្នុងសាលាគោលដៅ

នៅឆ្នាំ២០២៣ ជម្រាលចំនួន ១៥ ត្រូវបានសាងសង់ ក្នុងនោះមានជម្រាលសម្រាប់បង្គន់ចំនួន ៤ ជម្រាលសម្រាប់អគារសិក្សាចំនួន ១០ និងជម្រាលកន្លែងក្មេងលេងចំនួន ១ នៅក្នុងសាលាគោលដៅក្នុងស្រុកអង្គស្នួល កណ្តាលស្ទឹង សំរោងទង ច្បារមន និងស្រុកពួក។

សិស្សក្រៅសាលាដែលគ្មានពិការភាពចំនួន ១២៤នាក់ (ស្រី៖ ៦៦) បានទទួលអាហារូបករណ៍ដូចជា ឯកសណ្ឋាន សៀវភៅ និងកាបូប។

ដំណើរការថ្នាក់សមាហរណកម្ម ៥៤ថ្នាក់សម្រាប់កុមារមានពិការសតិបញ្ញា

ថ្នាក់សមាហរណកម្មចំនួន ៤៨ បានទទួលសម្ភារៈបង្រៀនដូចជា សៀវភៅរូបភាព សៀវភៅរឿង កន្ត្រែក្រដាសធំ ក្រដាសពណ៌ ផ្ទាំងរូបភាពអនាម័យ ផ្ទាំងរូបភាពលេខ ខ្មៅដៃ ដំរីលុប ប៊ិកហ្វឺត បង់ស្អិត។ល។

ការគាំទ្រថ្នាក់អប់រំបរិយាប័ន្ន តាមរយៈការផ្តល់សម្ភារសិក្សា និងជំនួយការបង្រៀន និងឧបករណ៍ជំនួយផ្សេងទៀតដល់ថ្នាក់អប់រំបរិយាប័ន្ន

ថ្នាក់បរិយាប័ន្នចំនួន ៤៦ថ្នាក់ បានទទួលសម្ភារៈបង្រៀនដូចជា សៀវភៅរូបភាព សៀវភៅរឿង កន្ត្រែ ក្រដាសធំ ក្រដាសពណ៌ ផ្ទាំងរូបភាពអនាម័យ ផ្ទាំងរូបភាពលេខ ខ្មៅដៃ ដំរៀបប ប៊ិកហ្វឺត បង់ស្អិត។ល។

ថ្នាក់បរិយាប័ន្នចំនួន ៥៩ (១៣ថ្នាក់ថ្មី និង ៤៦ថ្នាក់ចាស់) បានទទួលសម្ភារៈបង្រៀនដូចជា សៀវភៅរូបភាព សៀវភៅរឿង កន្ត្រែ ក្រដាសធំ ក្រដាសពណ៌ ផ្ទាំងរូបភាពអនាម័យ ផ្ទាំងរូបភាពលេខ ខ្មៅដៃ ដំរៀបប ប៊ិកហ្វឺត បង់ស្អិត។ល។

ចំនួនកុមារនិងយុវជនមានពិការភាព និងកុមារក្រៅសាលាសរុប គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣មានចំនួន៖ ២៩២៥នាក់ (ស្រី៖ ១៣៣៧)

ការគាំទ្រគ្រួសារកុមារក្រៅសាលាលើមុខរបរ សម្ភារ និងសេវា

គ្រួសារនៃកុមារពិការសតិបញ្ញាចំនួន ៦ គ្រួសារ បានផ្តល់ការគាំទ្រផ្នែកមុខរបរចិញ្ចឹមជីវិត ដូចជាបោកអ៊ុត ចិញ្ចឹមមាន់ និងបើកហាងលក់កាហ្វេ ក្នុងនោះ ២ គ្រួសារនៅភ្នំពេញ និង ៤ គ្រួសារនៅខេត្តសៀមរាប។ កុមារ និងយុវជនពិការសតិបញ្ញាចំនួន ៣៥នាក់ (ស្រី៖ ១៨) បានទទួលការបណ្តុះបណ្តាលជំនាញទន់ និងជំនាញរឹងក្នុងឆ្នាំ២០២៣។

លទ្ធផលទី ២៖ កុមារក្រៅសាលាបានទទួលការអប់រំកម្រិតបឋមប្រកបដោយគុណភាពនិងភាពប្រសើរឡើង។

ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយសៀវភៅអប់រំបរិយាប័ន្នមូលដ្ឋាន

សិក្ខាសាលាស្តីពីការអប់រំបរិយាប័ន្នចំនួន ៣ ត្រូវបានធ្វើឡើង ក្នុងនោះ ១លើក ធ្វើនៅស្រុកអង្គស្នួល ១ លើក នៅស្រុកសំរោងទង និង១លើកទៀត នៅស្រុកពួក៖

- **ស្រុកអង្គស្នួល៖** សិក្ខាសាលាអប់រំបរិយាប័ន្ន ធ្វើឡើងនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ ដោយមានសិក្ខាកាមចំនួន១៧នាក់ ក្នុងនោះមាននាយកសាលាចំនួន១៣នាក់ គ្រូអប់រំពិសេស១នាក់ និងបុគ្គលិកទន្សាយ ចំនួន៣នាក់។
- **ស្រុកសំរោងទង៖** សិក្ខាសាលាអប់រំបរិយាប័ន្នបានធ្វើឡើងនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ដោយមានសិក្ខាកាមចូលរួមចំនួន ១៨នាក់ រួមមាន អប់រំខេត្ត ១នាក់ អប់រំស្រុក ២នាក់ នាយកសាលា ១១នាក់ គ្រូពិសេស ២នាក់ និងបុគ្គលិកទន្សាយ ២នាក់។
- **ស្រុកពួក៖** សិក្ខាសាលាអប់រំបរិយាប័ន្ន ត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ដោយមានសិក្ខាកាមចំនួន ៣០នាក់ រួមមាននាយកសាលាចំនួន ១៥នាក់ គ្រូបង្រៀនពិសេសចំនួន ១០នាក់ អប់រំស្រុកចំនួន ១នាក់ អប់រំខេត្ត ចំនួន ១នាក់ និងបុគ្គលិកទន្សាយចំនួន ៣នាក់ ។ ជាលទ្ធផលនៃសិក្ខាសាលាអប់រំបរិយាប័ន្នទាំងបី អ្នកចូលរួមយល់ដឹងអំពីវិធីកំណត់អត្តសញ្ញាណ

កុមារដែលមានពិការភាពសតិបញ្ញា និងពិការភាពផ្សេងទៀតសម្រាប់ការចុះឈ្មោះចូលរៀន។ អ្នកចូលរួមក៏យល់ដឹងអំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនៃការអប់រំបរិយាប័ន្តផងដែរ។

ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីការអប់រំពិសេសសម្រាប់គ្រូបង្រៀនកុមារមានពិការសតិបញ្ញា នាយកសាលា និងក្រុមការងារគ្រប់គ្រងបច្ចេកទេសកម្រិតស្រុក

សិក្ខាសាលាស្តីពីការអប់រំពិសេសចំនួន ៣ ត្រូវបានធ្វើឡើង ក្នុងនោះ ១លើក ធ្វើនៅស្រុកអង្គស្នួល ១ លើក នៅស្រុកសំរោងទង និង១លើកទៀត នៅស្រុកពួក៖

- **ស្រុកអង្គស្នួល៖** សិក្ខាសាលាអប់រំពិសេស ធ្វើឡើងនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ ដោយមានសិក្ខាកាមចំនួន ២៤នាក់ ក្នុងនោះមាននាយកសាលាចំនួន១៣នាក់ គ្រូអប់រំបរិយាប័ន្តចំនួន ១៧ នាក់ គ្រូអប់រំពិសេសចំនួន ៤នាក់ និងបុគ្គលិកទន្សាយ ចំនួន៣នាក់។
- **ស្រុកសំរោងទង៖** សិក្ខាសាលាអប់រំពិសេស បានធ្វើឡើងនៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២៣ ដោយមានសិក្ខាកាមចូលរួមចំនួន ៣៦នាក់ រួមមាន អប់រំស្រុក ១នាក់ នាយកសាលា ១១នាក់ អប់រំបរិយាប័ន្តចំនួន ២២នាក់ គ្រូពិសេស ១០នាក់ និងបុគ្គលិកទន្សាយ ៣នាក់។
- **ស្រុកពួក៖** សិក្ខាសាលាអប់រំពិសេស ត្រូវបានធ្វើឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ដោយមានសិក្ខាកាមចំនួន ១២នាក់ រួមមាន គ្រូអប់រំបរិយាប័ន្តចំនួន ១០នាក់ និងបុគ្គលិកទន្សាយ ចំនួន ២នាក់។ ជាលទ្ធផលនៃសិក្ខាសាលាអប់រំពិសេសទាំងបី អ្នកចូលរួមយល់ដឹងអំពីវិធីកំណត់អត្តសញ្ញាណកុមារដែលមានពិការភាពសតិបញ្ញា និងពិការភាពផ្សេងទៀតសម្រាប់ការចុះឈ្មោះចូលរៀន។ អ្នកចូលរួមក៏យល់ដឹងអំពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនៃការអប់រំបរិយាប័ន្តផងដែរ។ គ្រូបង្រៀនទាំងអស់បានរៀន និងចែករំលែកចំណេះដឹង និងបទពិសោធន៍។ អ្នកចូលរួមយល់ពីរបៀបកំណត់អត្តសញ្ញាណកុមារដែលមានពិការភាពសតិបញ្ញា និងពិការភាពផ្សេងទៀត ហើយយល់ដឹងពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនៃការអប់រំបរិយាប័ន្តផងដែរ។
- វគ្គបណ្តុះបណ្តាលចំនួន ៣វគ្គ ស្តីពីការគ្រប់គ្រងអាកប្បកិរិយា ក្នុងនោះ ១វគ្គ ធ្វើនៅភ្នំពេញខេត្តកំពង់ស្ពឺ ១វគ្គ និងខេត្តសៀមរាប ១វគ្គ។ សរុបមានគ្រូបង្រៀនអប់រំពិសេស និងគ្រូបង្រៀនអប់រំបរិយាប័ន្ត ចំនួន១០០នាក់ (ស្រី៖ ៧០) ចូលរួមវគ្គបណ្តុះបណ្តាលទាំងបីនេះ។ ជាលទ្ធផល គ្រូបង្រៀនទាំងអស់បានរៀន និងចែករំលែកចំណេះដឹង និងបទពិសោធន៍គ្នាទៅវិញទៅមក។ អ្នកចូលរួមយល់ពីរបៀបកំណត់អត្តសញ្ញាណកុមារដែលមានពិការភាពសតិបញ្ញា និងពិការភាពផ្សេងទៀត ស្វែងយល់ពីវិធីសាស្ត្របង្រៀនជាយុទ្ធសាស្ត្រ និងការគ្រប់គ្រងអាកប្បកិរិយាដល់ការអប់រំកុមារដែលមានពិការភាពសតិបញ្ញា និងអូទីស្សឹម ក្នុងថ្នាក់បរិយាប័ន្ត និងថ្នាក់សមាហរណកម្ម។

ការរៀបចំកិច្ចប្រជុំគាំទ្របច្ចេកទេសគ្រូដើម្បីផ្តល់ការគាំទ្រដល់ថ្នាក់សមាហរណកម្មនិងអប់រំបរិយាប័ន្ននៅសាលាគោលដៅ

កិច្ចប្រជុំបច្ចេកទេសគ្រូបង្រៀនចំនួន ៣៦លើក ដែលក្នុងនោះ កិច្ចប្រជុំបច្ចេកទេសចំនួន ១៣លើក នៅរាជធានីភ្នំពេញ ៥លើក នៅស្រុកអង្គស្នួល ៤លើក នៅស្រុកកណ្តាលស្ទឹង ៤លើក នៅស្រុកសំរោងទង ៦លើក នៅស្រុកច្បាមន និង៤លើក នៅស្រុកពួក។ គ្រូអប់រំពិសេស និងគ្រូអប់រំបរិយាប័ន្នចំនួន ២៦០ នាក់ (ស្រី៖ ១៩០) បានចូលរួមក្នុងកិច្ចប្រជុំបច្ចេកទេសទាំងនេះ។

ការរៀបចំទស្សនៈកិច្ចត្រួតពិនិត្យ និងតាមដានសកម្មភាពការងារនៅក្នុងតំបន់គោលដៅ

ដំណើរចុះពិនិត្យសកម្មភាពចំនួន ១៧លើក ធ្វើឡើងដោយនាយកប្រតិបត្តិ ប្រធានគម្រោង និងមន្ត្រីត្រួតពិនិត្យ ដើម្បីពិនិត្យ និងតាមដានវឌ្ឍនភាពនៃគម្រោង ក្នុងនោះ ៣លើក នៅភ្នំពេញ ២លើក នៅស្រុកអង្គស្នួល ៣លើក នៅស្រុកកណ្តាលស្ទឹង ៣លើក នៅស្រុកសំរោងទង ៣លើក នៅស្រុកច្បាមន និង ៣លើក ទៀតនៅស្រុកពួក។ គ្រួសារកុមារពិការសតិបញ្ញាចំនួន ១២ គ្រួសារ ហើយមន្ត្រីចំនួន ៨១នាក់ (ស្រី៖ ២១) បានជួបប្រជុំគ្នា រួមមានលោកគ្រូ អ្នកគ្រូ នាយកសាលា ឪពុកម្តាយ និង សិស្សក្រៅសាលា មកពីសាលាគោលដៅចំនួន ៥៥សាលា។ ជាលទ្ធផល សកម្មភាពគម្រោងភាគច្រើនបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

លទ្ធផលទី ៣៖ សមត្ថកិច្ច និងសិទ្ធិកុមារក្រៅសាលា បានពង្រឹងការទទួលខុសត្រូវគ្នាទៅវិញទៅមក។

ការធ្វើយុទ្ធនាការតាមសាលារៀនដើម្បីចុះឈ្មោះកុមារក្រៅសាលាក្នុងតំបន់គោលដៅ

យុទ្ធនាការសាលាចំនួន ១១លើក ត្រូវបានរៀបចំឡើងនៅតាមស្រុកគោលដៅ ក្នុងនោះមាន ស្រុកអង្គស្នួល ២លើក ស្រុកកណ្តាលស្ទឹង ២លើក ស្រុកសំរោងទង ២លើក ស្រុកច្បាមន ២លើក និង ស្រុកពួក ៣លើក ។ អ្នកចូលរួម ៧៤៧នាក់ (ស្រី៖ ៣២២) រួមមានគ្រូបង្រៀន នាយកសាលា សិស្ស និងមេភូមិ បានចូលរួមក្នុងយុទ្ធនាការសាលាទាំងនេះ។ គោលបំណងនៃយុទ្ធនាការរបស់សាលាគឺដើម្បីផ្សព្វផ្សាយអំពីការចុះឈ្មោះកុមារក្រៅសាលាចូលរៀនក្នុងឆ្នាំសិក្សា ២០២៣-២០២៤។

ធ្វើយុទ្ធនាការកំណត់ផែនទីសាលាដើម្បីកំណត់អត្តសញ្ញាណកុមារក្រៅសាលា

ការកំណត់ផែនទីសាលាចំនួន ៣១លើក ត្រូវបានធ្វើឡើងដោយមាននាយកសាលាចំនួន ៣១នាក់ចូលរួម។ សិស្សក្រៅសាលាថ្មីចំនួន ១២៦១នាក់ (ស្រី៖ ៦១០) ត្រូវបានរកឃើញសម្រាប់គាំទ្រនៅក្នុងស្រុកគោលដៅទាំង៥។

ការរៀបចំទិវាអូទីស្សឹមអន្តរជាតិ

ព្រឹត្តិការណ៍ចំនួន៥ ត្រូវបានរៀបចំឡើងនៅរាជធានីភ្នំពេញ ស្រុកអង្គស្នួល ស្រុកកណ្តាលស្ទឹង និងស្រុកពួក៖

- **ភ្នំពេញ៖** ទិវាអូទីស្សឹម ត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមចំនួន ៣០នាក់ (ស្រី៖ ១៣) ក្នុងនោះសិស្ស ២៥នាក់ (ស្រី៖ ៨) និងបុគ្គលិក ៥នាក់ (ស្រី៖ ៥)។ ទិវាសិទ្ធិកុមារត្រូវបានរៀបចំនៅរាជធានីភ្នំពេញដោយមានអ្នកចូលរួមចំនួន ៨៨ (ស្រី៖ ២៣) មកពីសាលារៀនទន្សាយ ក្នុងនោះមានសិស្សចំនួន ៧០នាក់ (ស្រី៖ ១៣) និងបុគ្គលិកចំនួន ១៨ (ស្រី៖ ១០)។
- **ស្រុកកណ្តាលស្ទឹង៖** ទិវាអូទីស្សឹមបានធ្វើឡើងនៅសាលាបឋមសិក្សាក្រាំងកន្ធរ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមចំនួន ៦២៨នាក់ (ស្រី៖ ២៩៨) រួមមានសិស្សពិការ និងគ្មានពិការភាព លោកគ្រូ អ្នកគ្រូ គ្រូពិសេស នាយកសាលា មាតាបិតា និងអាជ្ញាធរមូលដ្ឋាន។ល។
- **ស្រុកអង្គស្នួល៖** ទិវាសិទ្ធិកុមារមួយត្រូវបានធ្វើឡើងនៅសាលាបឋមសិក្សាព្រៃពួច ដែលមានអ្នកចូលរួមចំនួន ១២៣ នាក់ (ស្រី៖ ៨៦) រួមមាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សដែលមាន និងគ្មានពិការភាព។
- **ស្រុកពួក៖** ទិវាសិទ្ធិនារី ត្រូវបានធ្វើឡើងនៅស្រុកពួក ខេត្តសៀមរាប តាមរយៈការជិះកង់ចម្ងាយ ៥គីឡូម៉ែត្រ ជាមួយសាលាបឋមសិក្សាចំនួន ៥ នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមចំនួន ៤៧៧នាក់ (ស្រី៖ ២៥៦)។

ការរៀបចំទិវាសិទ្ធិជនមានពិការភាពនៅក្នុងសហគមន៍និងថ្នាក់ជាតិ

- នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៣ សាលារៀនទន្សាយបាននាំយកសិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ ចំនួន ៣៨នាក់ (ស្រី៖ ២០) ទៅចូលរួមទិវាសិទ្ធិជនពិការជាតិ និងអន្តរជាតិ នៅសាលមហោស្រពកោះពេជ្រ ដែលរៀបចំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និយុវនីតិសម្បទា និង អង្គការជាតិ/អន្តរជាតិផ្សេងៗទៀត។ ពិធីនេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនិងអមដំណើរដោយរដ្ឋមន្ត្រី និងឯកអគ្គរាជទូតជាច្រើនរូប។
- ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣ សាលារៀនទន្សាយបានរៀបចំទិវាជនពិការជាតិ នៅស្រុកពួក ខេត្តសៀមរាប ដែលមានអ្នកចូលរួមចំនួន ១៥៣នាក់ (ស្រី៖ ២៥) រួមមាន សិស្ស/គ្មានពិការភាព លោកគ្រូ អ្នកគ្រូ នាយកសាលា ប៉ូលីស ការិយាល័យអប់រំ ការិយាល័យសង្គមកិច្ច មេឃុំបានចូលរួមព្រឹត្តិការណ៍នេះតាមរយៈការជិះកង់ជាមួយយើងនៅក្នុងសហគមន៍។
- ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ សាលារៀនទន្សាយបានរៀបចំទិវាសិទ្ធិជនពិការ នៅសំរោងទង ខេត្តកំពង់ស្ពឺ ដោយមានអ្នកចូលរួមចំនួន ១២៥ (ស្រី៖ ៥០) រួមមាន សិស្សមាន/គ្មានពិការភាព លោកគ្រូ អ្នកគ្រូ នាយកសាលា ប៉ូលីស ការិយាល័យអប់រំ ការិយាល័យសង្គមកិច្ច មេឃុំបានចូលរួមព្រឹត្តិការណ៍នេះតាមរយៈការជិះកង់ជាមួយយើងនៅក្នុងសហគមន៍។ គោលបំណងនៃព្រឹត្តិការណ៍នេះគឺដើម្បីផ្ញើសារទៅកាន់ជនពិការ និងក្រុមគ្រួសាររបស់ពួកគេអំពីការចុះឈ្មោះពិការភាព និងលើកកម្ពស់លទ្ធភាពទទួលបានការអប់រំសម្រាប់កុមារទាំងអស់ រួមទាំងកុមារពិការ

ផងដែរ និងស្វែងរកការគាំទ្រពីអាជ្ញាធរមូលដ្ឋាន អ្នកអប់រំ និងអ្នកពាក់ព័ន្ធ ដើម្បីគាំទ្រកុមារពិការឱ្យចូលរៀន។

ការរៀបចំការប្រជុំជាមួយឪពុកម្តាយនៅក្នុងតំបន់គោលដៅ

- កិច្ចប្រជុំមាតាបិតាបានធ្វើឡើងចំនួន ១១លើក ក្នុងនោះ ៣លើក នៅអង្គស្នួល ២លើក នៅកណ្តាលស្ទឹង ២លើក នៅស្រុកសំរោងទង ២លើក នៅស្រុកច្បារមន និង២លើកនៅស្រុកពួក។ សរុបមានអ្នកចូលរួមចំនួន ២០៨ (ស្រី៖ ១៤៥) បានចូលរួមក្នុងការប្រជុំទាំងនេះ។
- ការចុះសួរសុខទុក្ខនៅផ្ទះត្រូវបានធ្វើឡើងជំនួសឱ្យការរៀបចំកិច្ចប្រជុំឪពុកម្តាយដោយសារតែបរិការមានកម្រិត។ ការចុះសួរសុខទុក្ខនៅផ្ទះចំនួន ៨ ត្រូវបានធ្វើឡើងដោយអ្នកមើលការខុសត្រូវផ្នែក ៥នាក់ ដែលក្នុងនោះឪពុកម្តាយចំនួន ៤៥ (ស្រី៖ ២៧) បានជួបនៅផ្ទះរបស់ពួកគេ ហើយពិភាក្សាអំពីការសិក្សារបស់កូនពួកគេ។ គោលបំណងនៃដំណើរទស្សនកិច្ចនេះគឺដើម្បីតាមដាន និងលើកទឹកចិត្តសិស្សឱ្យទៅសាលារៀនឱ្យបានទៀងទាត់ដោយមានទំនួលខុសត្រូវល្អពីមាតាបិតាក្នុងសហគមន៍។

ការរៀបចំ និងផ្សព្វផ្សាយលើទំព័រការសែតជាតិ និងបោះពុម្ពព្រឹត្តិបត្រ

1. Promotion education right for children with disabilities
2. District governor pushed to local authorities to take more attention to citizen especially person with disabilities
3. Cycling for education for children
4. Aide et Action join Edubike to call Out-of-school children
5. Cycling campaign for education

ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីអំពីច្បាប់គោលនយោបាយ និងបទបញ្ជាពាក់ព័ន្ធកុមារក្រៅសាលា និងកុមារពិការសេតិបញ្ញា រួមទាំងការបណ្តុះបណ្តាលតស៊ូមតិ និងការរំលេចបំពានផ្លូវភេទក្នុងតំបន់គោលដៅ។

វេទិកាថ្នាក់ក្រោមជាតិចំនួន ២ ស្តីពីការអប់រំបរិយាប័ន្នបានធ្វើឡើងនៅក្រុងច្បារមននៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៣ និងស្រុកកណ្តាលស្ទឹងនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣៖

- **ក្រុងច្បារមន៖** សិក្ខាកាមចំនួន ១៩នាក់ (ស្រី៖ ៦) រួមមាន នាយកសាលាចំនួន ១៣នាក់ មកពីក្រុងច្បារមន និងសំរោងទង។ មន្ត្រីតំណាងការិយាល័អប់រំស្រុកចំនួន ២នាក់ នៃក្រុងច្បារមន និងសំរោងទង។ មន្ត្រីតំណាងមន្ទីរអប់រំ ចំនួន ១នាក់ និងបុគ្គលិកសាលារៀនទន្សាយ ចំនួន ៣នាក់។
- **កណ្តាលស្ទឹង៖** សិក្ខាកាមចំនួន ៣០នាក់ (ស្រី៖ ១២) រួមមាន នាយកសាលាចំនួន ១៧នាក់ គ្រូអប់រំបរិយាប័ន្នចំនួន ៦នាក់ មាតាបិតាសិស្សចំនួន ១នាក់។ មន្ត្រីតំណាងការិយាល័អប់រំស្រុក

ចំនួន ២នាក់ នៃក្រុងច្បារមន និងសំរោងទង។ មន្ត្រីតំណាងមន្ទីរអប់រំ ចំនួន ១នាក់ និងបុគ្គលិកសាលារៀនទន្សាយ ចំនួន ៣នាក់។ ជាលទ្ធផល អ្នកចូលរួមទាំងអស់បានរៀនអំពីការអប់រំពិសេស និងច្បាប់ពាក់ព័ន្ធ ព្រមទាំងរបាយការណ៍វឌ្ឍនភាពគម្រោង។

- ក្រោមកិច្ចសហប្រតិបត្តិការជាមួយ VOICE និង Liliand Fond និងក្រុមការងារគាំទ្រកុមារក្រៅសាលា វេទិកាថ្នាក់ក្រោមជាតិមួយស្តីអំពីឱកាសការងារបរិយាប័ន្នបានធ្វើឡើងនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ នៅខេត្តសៀមរាប។ សរុបអ្នកចូលរួម ១៤០នាក់ នៅក្នុងវេទិកាការងារបរិយាប័ន្ននេះ រួមមានអ្នកចូលរួម ៣៧នាក់ (ស្រី៖ ២៦) មកពីសាលារៀនទន្សាយ ដែលក្នុងនោះមានគ្រូអប់រំពិសេស ១០នាក់ យុវជនពិការ ៩នាក់ ឪពុកម្តាយ ៧នាក់ ប្រធានសហគមន៍ ២នាក់ នាយកសាលា ៣នាក់ តំណាងអប់រំស្រុក ១នាក់ អភិបាលស្រុក ១នាក់ តំណាងអប់រំខេត្ត ១នាក់ និងបុគ្គលិកទន្សាយចំនួន ២នាក់។ https://www.akp.gov.kh/kh/post/detail/287426

ការរៀបចំវេទិកាថ្នាក់ជាតិជាមួយស្ត្រីម្តាយ/ ក្មេងស្រីមានពិការភាពសតិបញ្ញា អ្នកដឹកនាំធុរកិច្ច និងអ្នកជំទៃទៀតមកពីវិស័យឯកជនដើម្បីធ្វើការតស៊ូមតិជាក់បញ្ចូលយុវជនមានពិការភាពសតិបញ្ញាក្នុងទីផ្សារការងារកម្ពុជា

ក្រោមកិច្ចសហប្រតិបត្តិការជាមួយ VOICE, Liliand Fond និងក្រុមការងារគាំទ្រកុមារក្រៅសាលា វេទិកាការងារថ្នាក់ជាតិមួយបានធ្វើឡើងនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ អ្នកចូលរួមចំនួន ២០២ (ស្រី៖ ៩៨) បានចូលរួមនៅក្នុងវេទិកាការងារបរិយាប័ន្ននេះ រួមមាន ជនពិការ ឪពុកម្តាយ គ្រូបង្រៀន មន្ត្រីសង្គមកិច្ចស្រុកខេត្តក្រសួង ទីភ្នាក់ងារជាតិមុខរបរនិងការងារ និងវិស័យឯកជន បានចូលរួមវេទិកានេះ។ http://mosvy.gov.kh/3-11-2023

- យុវជនពិការភ្នែកបានចែករំលែកទស្សនៈវិស័យរបស់គាត់សម្រាប់ការងារនាពេលអនាគត និងជំរុញឱ្យជនពិការទាំងអស់មានភាពរឹងមាំ និងមានចក្ខុវិស័យផ្ទាល់ខ្លួន។
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច បានផ្តល់អនុសាសន៍ដល់វិស័យឯកជនក្នុងការបង្កើនឱកាសការងារដល់ជនពិការ។
- ទីប្រឹក្សារបស់ PAFiD បានចែករំលែកបទពិសោធន៍ និងករណីសិក្សារបស់គាត់អំពីបរិយាកាសការងារដែលប្រែប្រួលសម្រាប់ជនពិការនៅក្នុងប្រទេសឥណ្ឌា។
- មូលនិធិសមធម៌សង្គមបានចែករំលែកព័ត៌មានអំពីរបៀបទទួលបានមូលនិធិ និងចូលរួមកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ។
- ទីភ្នាក់ងារជាតិមុខរបរ និងការងារ បានចែករំលែកការផ្គូផ្គងការងារ និងព័ត៌មានការងារសម្រាប់ជនពិការ។

ការសហការរៀបចំវេទិកាអប់រំបរិយាប័ន្នជាមួយក្រសួងអប់រំ និងភាគីពាក់ព័ន្ធ

ក្រោមការជួយជ្រោមជ្រែងពីអង្គការ Aid et Acton, Liliand Fond ក្រុមការងារគាំទ្រកុមារក្រៅសាលា និងសហការជាមួយ NEP, CRS, Kroursar Thmey, AAR Japan, HHC, Child Fund, RTI, Save the Children តំណាងមាតាបិតា វេទិកាជាតិមួយស្តីពីអប់រំបរិយាប័ន្នមួយត្រូវបានធ្វើឡើងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣ នៅការិយាល័យអប់រំខេត្តកំពត សរុបមានអ្នកចូលរួមចំនួន ២០០នាក់ (ស្រី៖ ៨០) មកពីក្រសួង/មន្ទីរ/ការិយាល័យអប់រំ នាយកសាលា គ្រូបង្រៀន និងតំណាងយុវជនពិការ។ https://www.phnompenhpost.com/national/collaboration-responsibility-key-to-inclusive-education

ការគៀគរការគាំទ្រ និងត្រួតពិនិត្យជាមួយក្រសួងអប់រំយុវជននិងកីឡាទាក់ទងនឹងការបង្កើនការគាំទ្រសម្រាប់សកម្មភាពនិងគម្រោងរបស់អង្គការសាលារៀនទន្សាយ

សាលារៀនទន្សាយបានដឹកនាំកិច្ចប្រជុំ និងសិក្ខាសាលាចំនួនបីដងជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិភាក្សាអំពីដំណើរការធ្វើសមាហរណកម្មសាលារៀនទន្សាយចូលក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល។

ចែករំលែកឯកសារ ឬកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវលើបញ្ហាកុមារក្រៅសាលា

Rabbit school joint cycling campaign on education for OOSC children

៣. បញ្ហាប្រឈម

ក្នុងការដំណើរការអនុវត្តគម្រោងឆ្នាំ ២០២៣ អង្គការសាលារៀនទន្សាយ ប្រឈមនឹងឧបសគ្គរារាំងមួយចំនួន ដែលចាំបាច់ត្រូវយកចិត្តទុកដាក់បន្ថែម និងឆ្លើយតបនាពេលអនាគត ដូចខាងក្រោម៖

- ធនធានសាលារៀននៅមានកម្រិត ដូចជា គ្រូបង្រៀនជំនាញ អាហារូបករណ៍ សម្ភារៈសិក្សា និងលទ្ធភាពប្រើប្រាស់ដើម្បីទាក់ទាញកុមារក្រៅសាលាឱ្យមកសាលារៀន។
- ឪពុកម្តាយសិស្សមានបញ្ហាសតិបញ្ញាមិនមានទំនុកចិត្តចំពោះឱកាសការងារនាពេលអនាគតសម្រាប់កូនរបស់ពួកគេ។ ឪពុកម្តាយចង់ទុកកូននៅផ្ទះ ជាជាងចូលរៀនថ្នាក់វិជ្ជាជីវៈ។
- ធនធានមានកម្រិតនៃកម្មវិធីសិក្សា និងគ្រូជំនាញ ដើម្បីធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់យុវជនដែលមានពិការភាពបញ្ញា
- និយោជកខ្លះប្រឈមនឹងការលំបាកក្នុងការទំនាក់ទំនងជាមួយនិយោជិតពិការ ដោយសារពួកគេមិនមានជំនាញទំនាក់ទំនងជាមួយជនពិការ។
- ជំនួយថវិកាមានការខ្វះខាតពីម្ចាស់ជំនួយ។
- ការយល់ដឹងអំពីប្រភេទនៃកុមារក្រៅសាលានៅមានកម្រិត និងខ្វះផែនការអភិវឌ្ឍន៍សាលាទាំងមូល។
- គ្រួសារកុមារធ្វើចំណាកស្រុក និងប្រាក់ចំណូលទាប។

៤. យុទ្ធសាស្ត្រ និងផែនការបន្ទាប់

- អង្គការសាលារៀនទន្សាយ នឹងរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់គ្រូបង្រៀនទូទៅទាំងអស់ក្នុងសាលារៀនស្តីអំពីការអប់រំពិសេស។
- យើងនឹងពង្រឹងសកម្មភាពលើកកម្ពស់ការយល់ដឹងដល់មាតាបិតា នាយកសាលា និងអាជ្ញាធរមូលដ្ឋានអំពីការកំណត់អត្តសញ្ញាណពិការភាព តម្រូវការរបស់កុមារក្រៅសាលា និងសិទ្ធិរបស់កុមារក្នុងការទទួលបានការអប់រំស្មើៗគ្នា។
- ការបញ្ចុះបញ្ចូល និងការតស៊ូមតិជាមួយអាជ្ញាធរមូលដ្ឋាន នាយកសាលា មន្ទីរការិយាល័យអប់រំ ដើម្បីបង្កើនការយកចិត្តទុកដាក់លើសិទ្ធិកុមារ ជាពិសេសការអភិវឌ្ឍន៍កុមារ។
- ផ្តល់ការប្រឹក្សាបន្ថែមដល់យុវជនដែលមានពិការភាពសតិបញ្ញា និងគ្រួសារអំពីអត្ថប្រយោជន៍នៃជំនាញវិជ្ជាជីវៈ និងកម្មសិក្សាជំនាញ។
- ធ្វើស្វែងរកមូលនិធិ គៀងគរម្ចាស់ជំនួយដើម្បីជានាការផ្តល់មូលនិធិរយៈពេលយូរ។

៥. និរន្តរភាព

- គ្រូបង្រៀនពិសេសទាំងអស់នៅក្នុងសាលាទន្សាយត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា ជាមន្ត្រីរាជការ និងមន្ត្រីកិច្ចសន្យា និងទទួលបានប្រាក់បៀវត្សរ៍បន្ថែម ៨០% ពីរាជរដ្ឋាភិបាល។

៦. សកម្មភាពពិនិត្យតាមដាន និងវាយតម្លៃ


- អង្គការសាលារៀនទន្សាយ បានធ្វើសកម្មភាពត្រួតពិនិត្យជាប្រចាំពីថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រង។ អ្នកគ្រប់គ្រងតាមដានសកម្មភាពប្រចាំថ្ងៃនៅក្នុងសាលាគោលដៅនីមួយៗ។
- លោកគ្រូអ្នកគ្រូត្រូវពិនិត្យប្រចាំថ្ងៃជាមួយសិស្សអំពីសកម្មភាពប្រចាំថ្ងៃ។
- មាតាបិតាតាមដានការរីកចម្រើនរបស់កូនរៀងរាល់ ៤ខែម្តង។
- អ្នកគ្រប់គ្រងកម្មវិធី និងមន្ត្រីត្រួតពិនិត្យវាយតម្លៃនៃសាលាទន្សាយ បានចុះត្រួតពិនិត្យរាល់ខែ ឬពិនិត្យក្រៅផ្លូវការតាមករណី។
- នាយកសាលាទន្សាយ និងអ្នកគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ ធ្វើផែនការរួមគឺអនុវត្តទាន់ពេល និងមានប្រសិទ្ធភាព។

៧. ការទំនាក់ទំនង និងការមើលឃើញនៃគម្រោង

- - ហ្វេសប៊ុក៖ https://www.facebook.com/profile.php?id=100057447746 72&fref=ts
- - គេហទំព័រ៖ www.rabbitschoolcambodia.net

៨. ករណីសិក្សា

ករណីសិក្សា កុមារ ងួន កែវបញ្ញាពង្ស
មានពិការភាពខ្សោយគំហើញ



កុមារ **ងួន កែវបញ្ញាពង្ស** អាយុ១២ឆ្នាំ មានពិការភាពខ្សោយគំហើញ មានស្រុកកំណើតនៅភូមិសំរោងយា ឃុំសំរោងយា ស្រុកពួក ខេត្តសៀមរាប មានចំងាយពីផ្សារពួកប្រហែល ៦០០០ ម៉ែត្រ។ សព្វថ្ងៃគាត់រស់នៅជាមួយឪពុកម្តាយដែលជាគ្រួសារដែលមានទ្រព្យធន។ ឪពុកឈ្មោះ ងួន វាសនា និងម្តាយឈ្មោះ កែវ កញ្ញានា ដែលមានមុខរបរជាអ្នកលក់ដូរ ហើយមានកូនបីនាក់ ពីរនាក់ជាប្អូនស្រី និងបញ្ញាពង្ស ជាកូនពៅ។ បញ្ហាខ្សោយគំហើញរបស់ បញ្ញាពង្ស គឺបណ្តាលមកពីជំងឺហង្សឺនមួយប្រភេទ ជាជំងឺសើស្បែក ដែលជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធភ្នែកតាំងពីគាត់មានអាយុ ៨ឆ្នាំ។ បញ្ញាពង្ស អាចមើលឃើញកាន់ច្បាស់លុះត្រាតែវត្ថុទាំងអស់មានទំហំសមស្រប ឬធំ នឹងមានចម្ងាយជិត។ ថ្ងៃអនាគត គាត់មានបំណងចង់ក្លាយជាវេជ្ជបណ្ឌិតផ្នែកជំងឺបេះដូង។

កុមារ ងួន កែវបញ្ញាពង្ស ថ្លែងថា៖ «ប្រាកដណាស់ខ្ញុំពិការ ប៉ុន្តែការសិក្សារបស់ខ្ញុំអត់ពិការទេ»។

នៅឆ្នាំ២០០៨ កុមារ បញ្ញាពង្ស បានទទួលការអប់រំកម្រិតបឋមសិក្សានៅសាលាបឋមសិក្សាអំពិល មានទីតាំងនៅជិតកន្លែងដែលគាត់រស់នៅ។ បច្ចុប្បន្ននេះ គាត់កំពុងរៀនថ្នាក់ទី៦។ បញ្ញាពង្ស ជាសិស្សឧស្សាហ៍ព្យាយាម សិក្សារៀនសូត្រទាំងក្នុងថ្នាក់ និងក្រៅថ្នាក់ ហើយសិក្សាច្រើនស្ទើរតែគ្រប់ពេលវេលា ជាពិសេសនៅពេលព្រឹកព្រលឹម គាត់តែងតែទន្ទេញមេរៀនដែលខ្លួនបានសិក្សា។ ដោយសារតែការខិតខំប្រឹងប្រែង បញ្ញាពង្សទទួលបានចំណាត់ថ្នាក់លេខ១ សម្រាប់ថ្នាក់ទី៦ នៃឆ្នាំសិក្សា ២០២២២០២៣ ដែលជាលទ្ធផលសិក្សាដ៏ល្អឥតខ្ចោះ។ គាត់មានអារម្ម-មណ៍សប្បាយរីករាយក្នុងការសិក្សា មានមិត្តភ័ក្តិ លោកគ្រូ អ្នកគ្រូ បងប្អូន ឪពុកម្តាយ យកចិត្តទុកដាក់ លើកទឹកចិត្តគាត់ និងរីករាយជាមួយស្នាដៃរបស់គាត់ ជាពិសេសគាត់បានតាំងចិត្តបន្តការសិក្សា។





តាំងពីចូលរៀននៅសាលាបឋមសិក្សា កុមារ ងួន កែវបញ្ញាពង្ស ទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំង ដែលរដ្ឋាភិបាលបានលើកកម្ពស់សិទ្ធិសេរីភាពក្នុងការអប់រំ ហើយនៅឆ្នាំ ២០២៣ អង្គការ Ade At Action បានផ្តល់សម្ភារៈបង្រៀន និងសិក្សាដែលសមស្របទៅនឹងតម្រូវការអប់រំពិសេស។ បញ្ញាពង្ស ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការសាលារៀនទន្សាយ ដែលបានពង្រឹងបន្ថែមលើសមត្ថភាពរបស់នាយកសាលា និងគ្រូបង្រៀនតាមរយៈកម្មវិធីអប់រំជាតិ។

ករណីសិក្សារបស់លោកស្រី ឡម តាំ

ការហ្វេនែក្តីស្រឡាញ់



លោកស្រី **ឡម តាំ** ភេទ ស្រី អាយុ ៣៤ឆ្នាំ លំនៅរស់នៅភូមិតាហុក ឃុំត្រីញ៉ែរ ស្រុកពួក ខេត្តសៀមរាប។ លោកស្រីមានកូនមានពិការភាព ២ នាក់ ប្រុស ១នាក់ ស្រី ១នាក់ ក្នុងបន្ទុកគ្រួសារ ហើយលោស្រីរស់នៅក្នុងផ្ទះឈើ ប្រក់ស័ង្កសី ក្រាលក្តារ ជញ្ជាំងស្លឹក។ សព្វថ្ងៃកូនទាំង ២នាក់ បានសូត្រៀននៅផ្ទះជំនួសការរៀននៅសាលា ដោយលោកគ្រូ អ្នកគ្រូបង្រៀនផ្ទើរមៀនមកកាន់កូនទាំង ២នាក់ តាមប្រព័ន្ធទូរសព្ទដៃ និងមានចុះបង្រៀនទៅដល់ផ្ទះផងដែរ ដោយសារពិបាកក្នុងការធ្វើដំណើរ។ កូនទាំង ២នាក់ មានពិការភាពកាយសម្បទា ធ្លាប់បានព្យាបាលនៅមន្ទីពេទ្យគន្ធបុប្ផា ពេទ្យកុមារអង្គរខេត្តសៀមរាប (មានបញ្ហាសាច់ដុំ) និងធ្លាប់បានទៅពិគ្រោះ ឬសិក្សាជំងឺនៅពេទ្យប្រទេសថៃ។



ទទួលបានការគាំទ្រពីអង្គការសាលារៀនទន្សាយនិងគាំទ្រពីគម្រោងរបស់អង្គការ PAFID លោកស្រីមានឱកាសចូលរួមសកម្មភាពទស្សនកិច្ចសិក្សា ប្រជុំចែករំលែកចំណេះដឹងជាមួយបងប្អូនមានពិការភាពដទៃទៀតផងដែរ។ បន្ទាប់ពីបានសិក្សាអំពីឱកាស ការចូលរួមពីក្រុមគ្រួសារលោកស្រីឃើញថា មានកន្លែងលក់ (ផ្ទះម្តាយបង្កើត) មានអ្នកម្តាយជាអ្នកជួយជំនួសដៃក្នុងការលក់ ពេលគាត់មានការរវល់ និង កូនមានពិការភាពជួយទូទាត់លុយបាន និងតំបន់រស់នៅមានភាពកុះករ អាចលក់ដូរបាន អាស្រ័យហេតុអង្គខាងលើ អង្គការបានផ្តល់ជូននូវគ្គបណ្តុះបណ្តាលជំនាញធុងការហ្វេ និងគាំទ្រមុខរបរការហ្វេដល់គាត់។



អារម្មណ៍ពិត របស់លោកស្រី ឡម តាំ៖ លោកស្រីប្រសាសន៍ កាលមិនបាមទាន់ទទួលបានការគាំទ្រពីអង្គការ លោកស្រីត្រូវពឹងផ្អែកទាំងស្រុងលើថវិការស្វាមីលោកស្រីរកបាន និងមិនសមមាត្រនោះទេ លើចំណាយ និងផ្គត់ផ្គង់គ្រួសារទេ លោកស្រីមិនអាចទៅប្រកបរបរផ្សេងដែលតម្រូវទុកកូនចោល និងដោយសារជំងឺពីកំណើររបស់លោកស្រីក៏មិនតម្រូវធ្វើការធ្ងន់លើសកម្លាំងផងនោះ។



លោកស្រីមានអារម្មណ៍សប្បាយចិត្តជាខ្លាំង បានការគាំទ្រពីអង្គការដែលបានគាំទ្រលើអាជីវកម្មជារបរខ្នាតតូចលោកស្រី ជាពិសេសអង្គការបានផ្តល់ការបង្រៀន រៀនលើចំណេះដឹង ចំណេះធ្វើ/ជំនាញ និងបានបើកមុខរបរនេះ អោយលោកស្រីមានលទ្ធិភាពរកប្រាប់ចំណូលនៅផ្ទះផង និងមានពេលវេលាគ្រប់គ្រាន់មើលថែទាំមកូនទាំង២ផងដែរ។

សូមអរគុណដល់អង្គការសាលារៀនទន្សាយ អេត អាក់ស្យុង វ៉ែយ និងអង្គការ PAFID ដែលបានជួយគាំទ្រនាងខ្ញុំ។

ឧបសម្ព័ន្ធ៖ រូបភាពសកម្មភាពផ្សេងៗ

រូបភាព៖ កសាងជម្រាលនិងជួសជុលបន្ទប់ទឹក









រូបភាព៖តម្លើងកន្លែងកុមាររលេងនៅសាលាបឋមសិក្សាទួលគោក





រូបភាព: សកម្មភាពផ្តល់អាហារូករណ៍សិស្ស







រូបភាព៖ សកម្មភាពចូលរួមទិវាសិទ្ធិជនមានពិការភាព











រូបភាព៖ ព្រឹត្តិការជិះកង់ (ពីភ្នំពេញ ទៅសៀមរាប)









រូបភាព៖ យុទ្ធនាការប្រមូលកុមារចូលរៀន







រូបភាព៖ សកម្មភាពចុះតាមផ្ទះ





